# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០០៩/២០ ក.ប/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រើប្រាស់គិលានដ្ឋានរួមនិងមូលដ្ឋានសុខាភិបាល ជំនួសការរៀបចំគិលានដ្ឋានប្រចាំសហគ្រាស គ្រឹះស្ថាន

យោងតាមការរីកចម្រើននៃវិស័យសុខាភិបាល និងការកើនឡើងនៃចំនួនមូលដ្ឋានសុខាភិបាល ក៏ដូចជាការដាក់ឱ្យដំណើរការផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពរបស់បេឡាជាតិរបបសន្តិសុខសង្គម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលស្ថិតក្នុងដែនអនុវត្តច្បាប់ស្តីពីការងារដែលជាប់កាតព្វកិច្ចអនុវត្តប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ឱ្យបានជ្រាបថា សហគ្រាស គ្រឹះស្ថានដែលពុំមានលទ្ធភាពក្នុងការរៀបចំគិលានដ្ឋានប្រចាំសហគ្រាស គ្រឹះស្ថានរបស់ខ្លួនអាចប្រើប្រាស់គិលានដ្ឋានរួម ឬអាចប្រើប្រាស់មូលដ្ឋានសុខាភិបាលជំនួសឱ្យការរៀបចំគិលានដ្ឋាន តាមលក្ខខណ្ឌដូចខាងក្រោម៖

១. សហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្នុងទីតាំងប្រមូលផ្តុំនិងមានចម្ងាយពីគ្នាមិនលើសពី ១ (មួយ) គីឡូម៉ែត្រ ឬសហគ្រាស គ្រឹះស្ថានដែលស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស អាចបង្កើតគិលានដ្ឋានរួមគ្នាមួយ។ គិលានដ្ឋានរួមនីមួយៗ ត្រូវបានប្រើប្រាស់សម្រាប់កម្មករនិយោជិតមិនលើសពី ១០ ០០០ (ដប់ពាន់) នាក់។

២. សហគ្រាស គ្រឹះស្ថានដែលមានបំណងប្រើប្រាស់មូលដ្ឋានសុខាភិបាលជំនួសការរៀបចំគិលានដ្ឋានប្រចាំសហគ្រាស ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- មូលដ្ឋានសុខាភិបាលនោះត្រូវមានការទទួលស្គាល់ដោយក្រសួងសុខាភិបាល និងមានចម្ងាយមិនលើសពី ២ (ពីរ) គីឡូម៉ែត្រពីសហគ្រាស គ្រឹះស្ថាននោះ
- ត្រូវជូនដំណឹងអំពីឈ្មោះ និងអាសយដ្ឋាននៃមូលដ្ឋានសុខាភិបាលមកនាយកដ្ឋានពេទ្យការងារ។

៣. សហគ្រាស គ្រឹះស្ថាននីមួយៗដែលប្រើប្រាស់គិលានដ្ឋានរួម ឬមូលដ្ឋានសុខាភិបាល ត្រូវរៀបចំឱ្យមានបន្ទប់វិរបូស និងគិលានុបដ្ឋាយិកាម្នាក់ ប្រចាំនៅក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួន។

៤. និយោជក ត្រូវរៀបចំឱ្យមានមធ្យោបាយសមស្រប ដើម្បីបញ្ជូនកម្មករនិយោជិតនៅពេលមានជំងឺឬគ្រោះថ្នាក់ការងារ ទៅគិលានដ្ឋានរួម ឬមូលដ្ឋានសុខាភិបាល។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ស្ថិតក្នុងដែនអនុវត្តច្បាប់ស្តីពីការងារដែលជាប់កាតព្វកិច្ចអនុវត្តប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាសនឹងអនុវត្តតាមខ្លឹមសារសេចក្តីជូនដំណឹងនេះបានត្រឹមត្រូវនិងមានប្រសិទ្ធភាព។

ថ្ងៃ សុក្រ ១៣កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០២០

រដ្ឋមន្ត្រី

អ៊ិត សំហេង

**កន្លែងទទួល** :

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-ក្រសួង ស្ថាប័នពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

-សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់

"ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ